# “ការងារបូកស៊ីម៉ងត៍និងបៀកស្រទាប់ខាងក្នុង”

ចំណុចសំខាន់សម្រាប់សុវត្ថិភាពនិងសុខភាព

## បម្រុងប្រយ័ត្នអំឡុងពេលសាងសង់ (រន្ទា, រន្ទាជណ្ដើ)

### (1) បម្រុងប្រយ័ត្ននៅពេលជញ្ជូនសម្ភារ

- ប្រើរទេះ, រទេះបេតុង, ។ល។ ដើម្បីដឹកជញ្ជូនសម្ភារ។ ការជញ្ជូនដោយបង្ខំអាចប៉ះពាល់ចង្កេះរបស់អ្នក។ ព្យាយាមកាត់បន្ថយការធ្វើទុក្ខចង្កេះរបស់អ្នកឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

[នៅពេលជញ្ជូនវត្ថុធ្ងន់]

ទីប្រជុំទម្ងន់នៃដងខ្លួននិងទីប្រជុំទម្ងន់នៃវត្ថុគួរតែស្ថិតនៅលើបន្ទាត់បញ្ឈរតែមួយ។

ទីប្រជុំទម្ងន់នៃដងខ្លួននិងទីប្រជុំទម្ងន់នៃវត្ថុគួរតែនៅជិតគ្នាតាមដែលអាចធ្វើទៅបាន។



របៀបលីសែង

របៀបកាន់លើក



## (2) សុវត្ថិភាពក្នុងការប្រើជណ្ដើរនិងតុការងារចល័ត

- គេគួរតែដាក់ជណ្ដើរនិងតុការងារចល័តនៅលើផ្ទៃរាបស្មើ និងពន្លាវារហូតទាល់តែក្បាលគន្លឹះឈប់។
- ផ្លែតហ្វមការងារនៃរន្ទាជណ្ដើរគួរតែទ្រនៅបីចំណុច, ចន្លោះនីមួយគួរតែមានប្រវែង 1.8 ម៉ែត្រ ឬតូចជាងនេះ និងហាមមនុស្សលើសពីពីរនាក់ស្ថិតនៅលើរន្ទានៅចន្លោះជើងកល់ក្នុងពេលតែមួយ។
- ការផ្គុំដំឡើងរន្ទារជណ្ដើរត្រូវធ្វើឡើងដោយអ្នកដែលបានបញ្ចប់ការបណ្ដុះបណ្ដាលពិសេស។

### [ឧទាហរណ៍អំពីរន្ទាជណ្ដើរ]



## (3) សុវត្ថិភាពក្នុងការឡើងនិងចុះពីតុការងារចល័ត

- ចូរដាក់ឧបករណ៍និងសម្ភារនៅលើរន្ទាជាមុនសិន សឹមឡើងនិងចុះយឺតៗដោយតោងរបារបង្កាន់ដៃឬកាំជណ្ដើរ។
- ហាមឡើងនិងចុះដោយបែរខ្នងទៅរកផ្ទៃតុហ្វមការងារ។



តោងរបារបង្កាន់ដៃនៅពេលឡើងនិងចុះ

## ( 4 ) រៀបចំផ្លូវដើរឲ្យមានសុវត្ថិភាពដោយទុកដាក់សម្ភារផ្សេងៗឲ្យមានសណ្ដាប់ធ្នាប់

នៅពេលប្រើតុការងារចល័តនៅតាមផ្លូវដើរ គេត្រូវតែរៀបចំរបស់របរឲ្យមានរបៀប ដើម្បីឲ្យបុគ្គលិកដទៃទៀតអាចប្រើផ្លូវនេះបាន។



## (5) ការឡើងនិងចុះជណ្តើរដោយប្រើដៃនិងជើងទាំងពីរ

ប្រសិនបើអ្នកប្រើស្លាបព្រាបូកឬក្តារបូកដោយដៃទាំងពីរ ហើយឡើងឬចុះជណ្តើរ អ្នកអាចបាត់បង់លំនឹងនិងធ្លាក់។ នៅពេលឡើងនិងចុះ, ហាមកាន់វត្ថុ និងប្រើដៃនិងជើងទាំងពីរដោយទប់បីចំណុច។



## (6) សុវត្ថិភាពក្នុងការប្រើប្រាស់ជណ្ដើរ

ប្រសិនបើអ្នកឈរនៅលើឬច្រកគាវនៅលើបន្ទះខាងលើជណ្ដើរ អ្នកអាចបាត់បង់លំនឹងដែលបណ្ដាលឲ្យដួលឬធ្លាក់។ ចូរប្រើវាឲ្យបានត្រឹមត្រូវ។

○ ហាមឈរឬច្រកគាវនៅលើបន្ទះផ្នែកខាងលើ។



× ការឈរលើបន្ទះខាងលើ និងការឈរច្រកគាវ



## (7) ហាមទុកដាក់របស់របរមិនចាំបាច់នៅលើរន្ទា

នៅពេលអ្នកបូកជញ្ជាំងនៅលើរន្ទា ឧបករណ៍អាចធ្លាក់ដោយចៃដន្យ ដូច្នេះចូរប្រាកដថាបានប្រយ័ត្នជើងរបស់អ្នកក្រែងលោមានឧបករណ៍ ឬវត្ថុមិនចាំបាច់ណាមួយស្ថិតនៅលើរន្ទា។ លើសពីនេះទៀត ចូរដំឡើងក្តារបាំងជើងឬសំណាញ់សុវត្ថិភាព។



## (8) ប្រយ័ត្នគ្រោះថ្នាក់ផ្ទាកក្រោយ!

- ប្រសិនបើទុកដាក់ឧបករណ៍នៅលើកម្រាល ឬអ្នកធ្វើការងារដោយកាន់វត្ថុធំមួយដែលជើងមើលមិនឃើញ នោះវាអាចបណ្ដាលឲ្យដួលដូចជា “ការជំពប់” ឬ “ការផុតជើង” ពីជណ្ដើរ។
- ចូរប្រាកដថាមិនបានទុកដាក់របស់របរនៅក្នុងផ្លូវដើរ និងហាមបំពេញការងារដោយជើងមើលមិនឃើញ។










